*ឯកសារព្រាង*

# ស្ថានភាពនៃការចិញ្ចឹមជីវិតក្នុងភូមិក្បាលរមាស ភាគឦសានប្រទេសកម្ពុជា

***DRAFT***

# Introduction to Livelihoods in Kbal Romeas Village, Northeast Cambodia



**សេចក្តីព្រាងខ** ស្ថានភាពនៃការចិញ្ចឹមជីវិតក្នុងភូមិក្បាលរមាសភាគឥសានប្រទេសកម្ពុជា

**ខែកុម្ភៈ ២០១៦**

បោះពុម្ពផ្សាយដោយ Mekong Watch សហការជាមួយអង្គការបណ្តាញការពារទន្លេបី (3S Rivers Protection Network)

**អង្គការ Mekong Watch**

អាគារ 3F Aoki ១-១២-១១ Taito, Taito-ku, Tokyo ១១០-០០១៦ ប្រទេសជប៉ុន

ទូរស័ព្ទទំនាក់ទំនង៖ +៨១ ៣ ៣៨៣២ ៥០៣៤

គេហទំព័រ៖ http://www.mekongwatch.org/index.html

សារអេឡិចត្រូនិច៖ info@mekongwatch.org

**អង្គការបណ្តាញការពារទន្លេបី** (3S Rivers Protection Network)

ក្រុងបានលុង ខេត្តរតនគីរី ប្រទេសកម្ពុជា

ទូរស័ព្ទទំនាក់ទំនង៖ +៨៥៥ ៧៥ ៩៧៤ ១១២

គេហទំព័រ៖ http://www.3spn.org/

សារអេឡិចត្រូនិច៖ info@3spn.org

**រូបថតដោយ៖** ដាំ សំណាង ភូ ប៊ុនថាន់ ប្រ៉ុច រិទ្ធី Fumiko Takahashi ថង សារិន និងអង្គការបណ្តាញការពារទន្លេបី

**សេចក្តីថ្លែងអំណរគុណ៖** ដាំ សំណាង ណែន ស៊ូគិត (3SPN) ភូ ប៊ុនថាន់ (3SPN) ប្រ៉ុច រិទ្ធី ថង សារិន និងអ្នកភូមិក្បាលរមាស

**មាតិកា**

សេចក្តីផ្តើម

ប្រវត្តិភូមិ

ការប្រើប្រាស់ដីធ្លី និងស្ថានភាពចិញ្ចឹមជីវិតនៅក្នុងភូមិ

ជំនឿលើអារុកអារក្សអ្នកតា

ប្រតិទិននៃការចិញ្ចឹមជីវិត និងបញ្ជីឈ្មោះឧបករណ៍នេសាទ និងធនធានធម្មជាតិ

ឧបសម្ព័ន្ធ១៖ ប្រតិទិននៃការចិញ្ចឹមជីវិតតាមរដូវកាលរបស់ភូមិក្បាលរមាស

ឧបសម្ព័ន្ធ២៖ ឧទាហរណ៍ពីប្រភេទត្រីក្នុងភូមិក្បាលរមាស

ឧបសម្ព័ន្ធ៣៖ ឧទាហរណ៍ពីឧបករណ៍នេសាទក្នុងភូមិក្បាលរមាស

ឧបសម្ព័ន្ធ៤៖ ឧទាហរណ៍ពីប្រភេទអនុផលព្រៃឈើក្នុងភូមិក្បាលរមាស

## សេចក្តីផ្តើម

ឯកសារនេះ រៀបរាប់ពីស្ថានភាពនៃការប្រើប្រាស់ធនធានធម្មជាតិប្រចាំថ្ងៃរបស់ប្រជាជនភូមិក្បាលរមាស និងពីជំនឿសាសនារបស់ពួកគេ។

កាលពីខែកក្កដា ឆ្នាំ២០១៤ អង្គការ Mekong Watch និងអង្គការបណ្តាញការពារទន្លេបី (3SPN) បានសហការជាមួយអ្នកភូមិ (រួមមានស្ត្រី ចាស់ទុំ សមាជិក/សមាជិកាក្រុមយុវជន។ល។ ដែលបន្តរស់នៅក្នុងភូមិទោះបីជាត្រូវរលំធ្វើស្រែ/ចំការ) រៀបចំធ្វើផែនទីកំណត់ទីតាំងធនធានធម្មជាតិមានប្រយោជន៍ ដែលមាននៅជុំវិញភូមិរបស់ពួកគាត់។ បន្ថែមពីលើនេះ កាលពីខែសីហា ឆ្នាំ២០១៥ បុគ្គលិកម្នាក់របស់អង្គការបណ្តាញទន្លេបី (3SPN) ឈ្មោះ ណែន ស៊ូគិត ដែលនាងជាប្រជាពលរដ្ឋខេត្តរតនគីរី និងជាអ្នកយល់ដឹងជ្រៅជ្រះពីវប្បធម៌ និងរបៀបរបបនៃការចិញ្ចឹមជីវិតរបស់ប្រជាជនក្នុងតំបន់ បានជួបសម្ភាសន៍អ្នកភូមិពីររូប រួមមានឈ្មោះ ដាំ សំណាង និង ឡាញ់ ស្រាង ហើយបានចងក្រងព័ត៌មានសម្ភាសន៍នេះជាឯកសារប្រតិទិនស្តីពីការចិញ្ចឹមជីវិតក្នុងភូមិ។ ជាមួយកិច្ចសហការនេះ រូបភាពធនធានធម្មជាតិ (ត្រី និងអនុផលព្រៃឈើ) ដែលបានចុះបញ្ជីពេលធ្វើផែនទីកំនត់ទីតាំង និងបទសម្ភាសន៍ត្រូវបានថតផ្តិតយក។ រូបថតទាំងនោះ នឹងត្រូវបង្ហាញនៅក្នុងតារាងឧបសម្ព័ន្ធនៃឯកសារនេះ។





## អំពីភូមិក្បាលរមាស




ភូមិក្បាលរមាស ស្ថិតនៅក្នុងឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង។ ភូមិនេះ ស្ថិតតាមបណ្តោយដងទន្លេស្រែពក (ជាភាសាព្នងអានថា វ៉ាឡាយស្រែពក)។ ភូមិក្បាលរមាស មានព្រំដែនរួមជាមួយភូមិស្រែគរ ភូមិក្របីជ្រុំ និងភូមិស្រែ ស្រណុក។ ភូមិនេះមានក្រឡាផ្ទៃ៥៥៥ ហ.ត និងមានប្រជាជនសរុប១២៧គ្រួសារ ដែលស្មើ៧៥០ នាក់។ ប្រជាជនក្នុងភូមិនេះ ភាគច្រើនជាជនជាតិដើមភាគតិចព្នង។

យោងតាមប្រពៃណីភូមិ ប្រជាជនភូមិក្បាលរមាស ធ្លាប់បានរស់នៅក្នុងភូមិមួយឈ្មោះ វ៉ឺន ចាន់ ដែលស្ថិតតាមដងទន្លេសេកុង។ កាលនោះ មានប្រជាជនតែ៣០គ្រួសារប៉ុណ្ណោះរស់នៅទីនោះ។ ក្នុងឆ្នាំ១៩៣៧ ពួកគេបានផ្លាស់ទីទៅកាន់ភូមិរុំពេរ (ប្រមាណ៧ គ.ម ភាគពាយព្យនៃភូមិសព្វថ្ងៃ និងស្ថិតក្នុងរង្វង់ដែនដីភូមិក្បាលរមាសបច្ចុប្បន្ន)។ ទោះបីជាយ៉ាងនេះក្តី ដោយសារ មានមនុស្សជាច្រើនបានស្លាប់ (អ្នកភូមិមានជំនឿយ៉ាងមុតមាំថា ការស្លាប់នេះជាបាតុភូតមួយដែលបង្កឡើងពីការខឹងសម្បាររបស់អារុកអារក្សអ្នកតា ចំពោះមនុស្សដែលល្មើសតំណមរបស់ខ្លួន) នៅឆ្នាំ១៩៧៣ ពួកគេក៏បានវិលមករស់នៅក្នុងភូមិក្បាលរមាសវិញ។ កាលនោះ អ្នកភូមិបានឃើញសត្វរមាសមួយក្បាលស្លាប់ក្នុងថ្លុកត្រពាំងមួយដ៏ធំ។ អ្នកភូមិក៏ចាប់ផ្តើមហៅត្រពាំងនេះថា ត្រពាំង **ក្បាលរមាស** ហើយក្រោយៗមកភូមិនេះក៏ត្រូវបានហៅថាភូមិក្បាលរមាសតែម្តង។

ចាប់តាំងពីមានការសាងសង់ទំនប់នៅប្រទេសវៀតណាម នៅខ្សែទឹកភាគខាងលើនៃទន្លេស្រែពក អ្នក

ភូមិជាច្រើនបានទទួលរងការឈើចាប់ឥតឈប់ឈរពីចរន្តទឹកគង្គុកភ្លាមៗ ដែលធ្វើអោយមានការបាក់ច្រាំងទន្លេព្រមទាំងធ្វើឲ្យមានកំណកកករទឹក និងបំពុលទឹកផងដែរ។ ការនេសាទ នៅតែដំណើរការធម្មតា ប៉ុន្តែបរិមាណផលចាប់បានធ្លាក់ចុះគួរឲ្យបារម្ភ ជាពិសេសចាប់តាំងពីទំនប់ត្រូវបានសាងសង់។

ជាងនេះទៀត ភូមិនេះស្ថិតនៅក្នុងរង្វង់អាងស្តុកទឹករបស់ទំនប់សេសានក្រោម២ ដែលបានសាងសង់ក្នុងឆ្នាំ២០១៤ថ្មីៗនេះ ហេតុដូចនេះ ភូមិនេះត្រូវប្រឈមមុខចំពោះការផ្លាស់ប្តូរទីតាំង។ ទោះបីជាយ៉ាងនេះក្តី អ្នកភូមិជាច្រើន មិនចង់បោះបង់ទន្លេ និងភ្នំរបស់ពួកគេទេ ម្យ៉ាងទៀត ដោយសារពួកគេគិតថាផ្នូរកប់ខ្មោចដូនតា និងទីសក្ការៈបូជារបស់ពួកគេ មិនអាចត្រូវបំផ្លាញ និងសាងសង់ថ្មីឡើងវិញនៅទីតាំងថ្មីបាន ដូចនេះ ពួកគេបាននឹងកំពុងបដិសេធ មិនព្រមចាកចេញពីទីតាំងចាស់របស់ពួកគេទេ បើគិតមកដល់ខែមករា ឆ្នាំ២០១៦នេះ។

## ការប្រើប្រាស់ដីធ្លី និងស្ថានភាពចិញ្ចឹមជីវិតនៅក្នុងភូមិ



អ្នកភូមិភាគច្រើនរស់នៅដោយពឹងផ្អែកទៅលើធនធានធម្មជាតិ និងធ្វើកសិកម្ម ដូចជាធ្វើស្រែ/ចំការ ចិញ្ចឹមសត្វ នេសាទត្រី ប្រមូលអនុផលព្រៃឈើ និងបរបាញ់ជាដើម។ ទីកន្លែងសំខាន់ៗសម្រាប់ពួកគេប្រកបរបរ គឺនៅក្នុងព្រៃ តាមទន្លេ អូរ ត្រពាំង វាលស្រែ និងតំបន់ដាំដុះផ្សេងៗទៀត។

ព្រៃឈើគឺជាទីកន្លែងដែលប្រជាជនអាចប្រមូលអនុផលព្រៃឈើ ទាំងអាចហូប និងមិនអាចហូបបាន។ មានតំបន់ព្រៃខ្លះ ត្រូវបានចាត់ទុកជាព្រៃឈើពិសេស សម្រាប់ធ្វើជាទីកន្លែងសក្ការៈរបស់ពួកគេ។ តំបន់ព្រៃដែលមានលក្ខណៈពិសេសនេះ នឹងមានបង្ហាញខាង ក្រោម។

ទន្លេក៏ជាប្រភពទឹកដ៏មានសារៈប្រយោជន៍សម្រាប់អ្នកភូមិផងដែរ ព្រោះវាជាទីកន្លែងដែលពួកគេអាចងូតទឹក បោកសំលៀកបំពាក់ និងធ្វើការស្រោចស្រពផលដំណាំផ្សេងៗ។ ម្យ៉ាងទៀត ក្រៅពីដើរតួនាទីជាបណ្តាញដឹកជញ្ជូនដ៏ចាំបាច់ហើយនោះ ទន្លេក៏ជាទីកន្លែងដែលអាចផ្តល់ម្ហូបអាហារផងដែរ ដូចជាត្រី ពពួកគ្រំ លាស ខ្ទៅ ខ្ចង ។ល។ ចំណែកស្រែវិញ ក៏សំខាន់ណាស់ដែរ គឺវាជាទីកន្លែងផលិតដំណាំស្រូវដែលជាអាហារមូលដ្ឋានរបស់ប្រជាជន ហើយវាក៏ជាទីកន្លែងផ្តល់ចំនីដល់សត្វចិញ្ចឹមដែរ ពិសេសនៅរដូវប្រាំង។ តំបន់ដីសើមមួយចំនួន ក៏ត្រូវបានប្រើប្រាស់ជាស្រែផងដែរ គឺរុក្ខជាតិដែលដុះលូតលាស់នៅក្នុង និងជុំវិញតំបន់ដីសើមនោះត្រូវគេយកមកធ្វើជាអាហារ និងប្រើក្នុងគោលបំណងផ្សេងៗទៀតជាច្រើន។

ប្រជាជនក្នុងភូមិនេះ ធ្វើស្រែគ្រាន់តែដើម្បីចិញ្ចឹមជីវិតតែប៉ុណ្ណោះ។ ស្រូវត្រូវគេដាំនៅទីកន្លែងពីរផ្សេងគ្នា ស្រូវចំការ/ស្រូវបុកដាំ និងស្រូវស្រែ/ស្រូវស្ទូង។ មានអ្នកភូមិខ្លះលក់ស្រូវដែលដាំបានទៅឲ្យគ្រួសារណាដែលមិនមានស្រូវគ្រប់គ្រាន់សម្រាប់ហូប ប៉ុន្តែមិនលក់ចេញទៅខាងក្រៅភូមិទេ។ ប្រភេទពូជស្រូវ៣យ៉ាងដែលគេដាំជាស្រូវចំការ/ស្រូវបុកដាំ រួមមានស្រូវកន្ទ្រប់ ដែលជាប្រភេទស្រូវស្រាល (អាយុកាល២ខែកន្លះ) ស្រូវការ៉េត និងស្រូវកន្ត្រែ ដែលជាស្រូវកណ្តាល (អាយុកាល៣ខែ)។ ស្រូវកន្ទ្រប់មានក្លិនក្រអូប ចំនែកឯស្រូវកន្ត្រែវិញមានទាំងក្លិនក្រអូប និងឱជារសឆ្ងាញ់។ ឧបករណ៍ធ្វើស្រែរបស់ពួកគេ រួមមានដងឈើទ្រវែងស្រួចចុង ដែលគេប្រើដើម្បីបុកដី ដាក់គ្រាប់ស្រូវ និងធុងធ្វើពីឫស្សីដែលប្រើសម្រាប់ដាក់គ្រាប់ស្រូវ។ នៅឆ្នាំដំបូងនៃវដ្តដំណាំស្រូវចំការ/ស្រូវបុកដាំ ដើមឈើតូចៗ ព្រៃរបោះ និងស្មៅ ត្រូវកាប់កំទេចចោលនៅខែកុម្ភៈ រួចដុតនៅខែមេសា។ ការកំចាត់ស្មៅចង្រៃរបស់ស្រូវ ត្រូវធ្វើនៅខែឧសភា បន្ទាប់មកនៅខែមិថុនា ទើបប្រជាជនចាប់ផ្តើមព្រួស/បុកដាំស្រូវ។

នៅក្នុងរង្វង់ដីស្រែបុកដាំ/ព្រួស ក៏មានដាំដំណាំល្ពៅ ឃ្លោក ននោង ស្លឹកគ្រៃ រុំដេង ម្ទេស ត្រប់ សណ្តែកគួរ និងត្រសក់ផងដែរ ពិសេសនៅតាមដីជំរាលដែលទំនេរអត់មានដាំស្រូវ។ ចំការស្រែមិនត្រូវបានប្រើប្រាស់ដើម្បីដាំស្រូវតែមួយមុខទេ ប៉ុន្តែក៏មានដាំបន្លែបង្កាលក្នុណៈគ្រួសារផងដែរ។

នៅក្នុងស្រូវស្រែ/ស្រូវស្ទូងវិញ ប្រជាជននិយមដាំពូជស្រូវស្រាលអាយុកាល៣ខែ ស្រូវកណ្តាលអាយុកាល៤ខែ និងស្រូវធ្ងន់អាយុកាល១ឆ្នាំ។ ពូជស្រូវកណ្តាលមួយប្រភេទ ឈ្មោះស្រូវស្កិនមានគ្រាប់រឹង និងមិនមានឱជារស់ឆ្ងាញ់ទេ។ ទោះជាយ៉ាងនេះក្តី អ្នកភូមិនៅតែដាំស្រូវនេះ ព្រោះវាផ្តល់ទិន្នផលខ្ពស់ និងអាចដុះលូតលាស់ល្អលើដី គ្រប់ប្រភេទ។ ពូជស្រូវនេះ ត្រូវគេស្ទូងក្នុងរង្វង់ខែកក្កដា ឬពេលខ្លះបន្ទាប់ពីភ្លៀងចាប់ផ្តើមធ្លាក់។ អ្នកភូមិ ក៏មានដាំដំណាំស្វាយចន្ទី និងដំឡូងមីផងដែរ ដើម្បីរកចំនូលបន្ថែម។ អ្នកភូមិ ក៏មានរក្សាទុកសួនដំណាំនៅជិតផ្ទះរបស់ពួកគេផងដែរដែលភាគច្រើនពួកគេដាំរុក្ខជាតិឱសថ បន្លែស្លឹក និងបន្លែផ្សេងៗទៀតសម្រាប់ជាអាហារប្រចាំថ្ងៃ។

ក្រៅពីដាំស្រូវ កសិករភាគច្រើនក្នុងភូមិក្បាលរមាសក៏ចិញ្ចឹមសត្វផងដែរ ដូចជាសត្វមាន់ ទា ជ្រូក និងគោ/ក្របីសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ និងសម្រាប់លក់ដើម្បីរកចំនូលផ្គត់ផ្គង់គ្រួសារបន្ថែម។

នៅក្នុងភូមិ ប្រជាជនប្រើឧបករណ៍នេសាទ៨ប្រភេទផ្សេងៗគ្នា។ ឧបករណ៍នេសាទប្រភេទផ្លែសន្ទូច ត្រូវបានប្រជានេសាទ បែងចែកជា៨ប្រភេទផ្សេងៗគ្នា (សូមមើលឧបសម្ព័ន្ធ៣៖ ឧទាហរណ៍ពីឧបករណ៍នេសាទភូមិក្បាលរមាស)។

មានអនុផលព្រៃឈើជាច្រើនប្រភេទ ដែលគេអាចរកបាននៅក្នុងភូមិ។ ប្រភេទអនុផលសំខាន់ៗ រួមមានពពួកផ្លែឈើហូបបាន ពពួកផ្សិតហូបបាន ប្រភេទអនុផលប្រើជាថាមពល និងប្រភេទអនុផលដែលគេប្រើជាសម្ភារះប្រើប្រាស់ (សូមមើលឧបសម្ព័ន្ធ៤៖ ឧទាហរណ៍ពីអនុផលព្រៃឈើភូមិក្បាលរមាស)។ ក្រៅពីព្រៃឈើ អ្នកភូមិក៏បានអនុវត្តការស្វែងរកផល និង អនុផលពីទន្លេ

តាមមាត់ទន្លេព្រមទាំងនៅតាមស្រែផងដែរ។ ការបរបាញ់ក៏ត្រូវបានអនុវត្តផងដែរនៅក្នុងព្រៃ។

**ជំនឿលើអារុក្សអារក្ស អ្នកតា**

ក្នុងភូមិនេះ មានកន្លែងជាច្រើន ដែលអ្នកភូមិចាត់ទុកជាកន្លែងសក្ការៈសម្រាប់គោរពបូជា ហើយពួកគេហៅទីកន្លែងទាំងនោះថាជាតំបន់ **អ្នកតា** គង់នៅ។ **អ្នកតា** គឺជាដួងព្រលឹង ឬ វិញ្ញាណដែលសន្ថិតនៅទីកន្លែងណាមួយ។



នៅក្នុងភូមិក្បាលរមាស មានទីកន្លែងជាច្រើនដែលគេចាត់ជាកន្លែងសក្ការៈ រួមមានអ្នកតារុំពេរលើ អ្នកតារុំពេរកណ្តាល អ្នកតារុំពេរក្រោម អ្នកតាត្រពាំងថ្ម អ្នកតាក្បាលភ្នំ អ្នកតាភ្នំរឿង អ្នកតាស្រែវែង អ្នកតាឫស្សី អ្នកតាស្រែក្រាញ់ អ្នកតាស្នែងក្របី អ្នកតាផ្អែម អ្នកតាស្រែកេសកុំ អ្នកតាស្រែពក និងអ្នកតាកុតប៊ូ។ អ្នកភូមិជឿថា មានដួងព្រលឹង/វិញ្ញាណរស់នៅតាមតំបន់ទាំងអស់នេះ។ លើសពីនេះ ទីកន្លែងមួយចំនួន ដូចជាទួល យាយកែវ និងរុំពេរកណ្តាល ត្រូវគេស្គាល់ថាជាតំបន់ព្រៃកប់ខ្មោច។ ជំនឿទាំងអស់នេះ ត្រូវបានកំណត់តាមប្រពៃណីក្រុមជនជាតិរបស់ពួកគេ ហើយប្រជាជនទៅធ្វើពិធីបន់ស្រន់ និងគោរពបូជានៅទីនោះជាញឹកញាប់ ដើម្បីសុំសេចក្តីសុខចំរើនក្នុងគ្រួសារ។

អ្នកតាក្បាលភូមិៈ ស្ថិតនៅជាប់ខាងក្រៅតំបន់មនុស្សរស់នៅក្នុងភូមិ ចំនែកឯទីអាស្រមរបស់ព្រលឹង/វិញ្ញាណវិញ ស្ថិតនៅមាត់ច្រកចូលភូមិតែម្តង។ អ្នកភូមិភាគច្រើនប្រកាន់ខ្ជាប់តាមប្រពៃណី និងធ្វើការបន់ស្រន់ដល់ដួងព្រលឹង/វិញ្ញាណទាំងនោះតាមទំនៀមទំលាប់ដោយសេចក្តីជ្រះថ្លា។ ពួកគេធ្លាប់រៀបចំពិធីឡើងអារក្សអ្នកតា ជាពិសេសនៅពេលគោ/ក្របីរបស់ពួកគេបានបាត់ ឬនៅពេលពួកគេមានបញ្ហា ឬកើតជម្ងឺផ្សេងៗ។ នៅពេលពួកគេចេញទៅស្រែ ឬពេលពួកគេវិលចូលភូមិវិញ ពួកគេក៏ត្រូវធ្វើពិធីបន់ស្រន់ដល់អារក្សអ្នកតាផងដែរ។

**ចំពោះទីតាំងវិញ អ្នកភូមិបានរៀបរាប់ពីរឿងរ៉ាវដូចខាងក្រោម៖**



កាលពីព្រេងនាយ មានអារក្សដែលគេស្គាល់ថាជា **អ្នកតាវិន** ចូលមកពន្យល់សពអ្នកភូមិដោយនិយាយថា គាត់ចង់រស់នៅជាមួយអ្នកភូមិ ហើយបានសុំឲ្យអ្នកភូមិសាងសង់ទីអាស្រមមួយសម្រាប់គាត់។ គាត់បាននិយាយថា គាត់នឹងនៅថែរក្សាអ្នកភូមិ និងធានាពីសេចក្តីសុខសុភមង្គលជូនចំពោះអ្នកភូមិគ្រប់ៗគ្នា។ នៅពេលនោះ ប្រជាជនក៏មិនបង្អង់យូរដែរ បាននាំគ្នារៀបចំសាងសង់ទីអាស្រមមួយជូនគាត់។ ចាប់តាំងពីពេលនោះមក អ្នកភូមិទាំងអស់ ពិតជាបានរស់នៅដោយសុខសន្តិភាព ហើយពួកគេបានជឿ និងធ្វើការបន់ស្រន់ចំពោះអារក្សនោះជារៀងរហូតមក។ ក្រោយមក អ្នកភូមិបានផ្លាស់ប្តូរឈ្មោះអារក្សនេះ ពី **អ្នកតាវិន** ទៅជា **អ្នកតាក្បាលភ្នំ** ជំនួសវិញ។

ប្រជាជនភូមិក្បាលរមាស ជឿថាប្រសិនបើគ្មានអ្នកតាក្បាលភ្នំទេ ជីវិតរបស់ពួកគេក៏មិនមានសុវត្ថិភាព ហើយពួកគេក៏មិនអាចបានសុខដែរ។ ជំនឿលើអ្នកតាក្បាលភ្នំគឺមានសារៈសំខាន់បំផុតចំពោះអ្នកភូមិ ក្នុងការបញ្ជាក់ពីអត្តសញ្ញាណរបស់ពួកគេជាក្រុមកុលសម្ព័ន្ធភាគតិចព្នង។

ព្រៃកប់ខ្មោច៖ នៅពេលនរណាម្នាក់លាចាកលោកនេះទៅ សាកសពនឹងត្រូវគេយកទៅកប់នៅក្នុងព្រៃកប់ខ្មោចដោយឥតមានការបូជាឡើយ។ អ្នកភូមិភាគច្រើន មិនដឹងច្បាស់ថាតើព្រៃកប់ខ្មោចនេះធំប៉ុណ្ណានោះទេ ប៉ុន្តែវាពិតជាធំគួរសម្យ។ នៅតំបន់ខ្លង់រាបកប់ខ្មោចនេះ មានពាងទឹក មានឆ្នាំង ចាន ខោអាវ ទង់រៀងក្រពើ និងវត្ថុផ្សេងៗ ដែលជានិមិត្តរូបតំណាងឲ្យវាលកប់ខ្មោច។ ព្រៃកប់ខ្មោចនេះ ត្រូវបានគេជឿថាជាទីកន្លែងដែលដួងព្រលឹង ឬវិញ្ញាណដូនតា ដែលបានចែកឋានទៅហើយស្ថិតនៅ។ អ្នកភូមិជឿថា ដួងព្រលឹង/វិញ្ញាណទាំងនេះ នៅវិលវល់មិនបានចាកចេញទៅកាន់ភពថ្មី។ ម្យ៉ាងទៀត

ប្រសិនបើមនុស្សម្នាក់បានប្រព្រឹត្តរឿងខុសឆ្គង ដូចជាលួចពាងទឹក ឆ្នាំងដាំបាយ ឬចាន ឬសាងសង់អាស្រមថ្មីឲ្យព្រលឹង/វិញ្ញាណនោះ
អ្នកនោះនឹងតម្រូវឲ្យសុំខមាទោសចំពោះទង្វើដែលខ្លួនបានធ្វើ ដោយធ្វើការសែនថ្វាយជាជ្រូក ឬគោ/ក្របី ដើម្បីសុំកុំឲ្យជួបបញ្ហាគ្រោះភ័យផ្សេងៗ។

**DRAFT Introduction to Livelihoods in Kbal Romeas Village, Northeast Cambodia**

February 2016

Published by Mekong Watch in cooperation with 3S Rivers Protection Network

Mekong Watch
3F Aoki Building 1-12-11 Taito, Taito-ku, Tokyo 110-0016 Japan
Tel: +81 3 3832 5034
Website: http://www.mekongwatch.org/index.html
E-mail: info@mekongwatch.org

3S Rivers Protection Network
Banlung Town, Ratanakiri Province, Cambodia
Tel: +855 75 974 112
Website: http://www.3spn.org/
E-mail: info@3spn.org

Photos: Samnang Dam, Bunthann Phou, Rithy Pruch, Fumiko Takahashi, Sarin Thong, and 3S Rivers Protection Network

Special thanks to: Samnang Dam, Soukit Nen (3SPN), Bunthann Phou (3SPN), Rithy Pruch, Sarin Thong, and Kbal Romeas Village

Table of contents：

**Introduction**

**About the village**

**Land use and livelihood of the village**

**Belief in spirits**

**Livelihood Calendar and List of Tools and Natural Resources**

**Appendix 1: Kbal Romeas Village Seasonal Livelihood Calendar**

**Appendix 2: Examples of Kbal Romeas Village Fish**

**Appendix 3: Examples of Kbal Romeas Village Fishing Gear**

**Appendix 4: Examples of Kbal Romeas Village NTFPs**

## Introduction

This catalog is an introduction to the natural resources used in the daily lives of the people of Kbal Romeas Village, and their beliefs.

In July 2014, Mekong Watch and the 3S Rivers Protection Network (3SPN), in collaboration with the villagers (women, the elderly, members of the youth group, etc. who remain in the village even during the busy farming season), mapped locations where natural resources considered by the villagers to be important exist in the surroundings of the village. In addition, in August 2015, a member of the 3SPN staff, who is herself a resident of Ratanakiri Province, and who has a deep understanding of the culture and livelihoods of the region, Soukit Nen, interviewed two of the villagers, Samnang Dam and Lanh Srang, and compiled a livelihood calendar of the village. With the cooperation of the villagers, photographs of the natural resources (fish and non-timber forest products) that were listed during the mapmaking and interviews were taken and these are shown in the appendices to this report.





## About the village




Kbal Romeas Village is located in Kbal Romeas Commune, Sesan District, Stung Treng Province. The village is along the Srepok River (Ralay Srepok in the Bunong language). Kbal Romeas village shares boundaries with Sraekor Village, Krobey Chrom, and Srae Sranok Village. The total land area of the village is 555 hectares. Kbal Romeas Village currently has a total population of 127 families, 750 people. The villagers are mainly of Bunong ethnicity.

According to village tradition, the villagers of Kbal Romeas once lived in a village called “Veun Chan” along the Sekong River. There were only 30 families living there. In 1937, they moved to Rompe Village (about 7 km southwest of the present village and within the boundaries of the current Kbal Romeas Village). However, as many people died there (the villagers strongly believe that this

was a phenomenon caused by the anger of spirits toward people who broke the taboos), in 1973 they came to live in Kbal Romeas Village. There was a big pond in which a rhinoceros was seen by the villagers to have died. The villagers started to call this pond Trapeang Kbal Romeas (Pond of the Rhinoceros Head), and thereafter called this village Kbal Romeas.

Since the construction of the dams in Vietnam, in the upper reaches of the Srepok River, the villagers have suffered from sudden fluctuations in the river water level and the associated river bank collapses, as well as water turbidity and pollution. Fishing is still widely practiced in the village, but fish catches have declined dramatically since the dams were built.

Moreover, the village lies within the reservoir of the Lower Sesan 2 Dam, the construction of which began in 2014, and is therefore targeted for relocation. Many of the villagers, however, do not want to abandon their rivers and mountains, and because they consider that the graves of their ancestors and their spirit shrines cannot be dismantled and reconstructed in a different location, are refusing to relocate as of January 2016.

## Land use and livelihood of the village

The villagers are greatly dependent on natural resources and earn their living by farming, rearing animals, fishing, gathering and hunting. Important places for them are forests, river, streams, ponds, rice fields, and other farmland.



The forests are places where edible and non-edible NTFPs are gathered and fuelwood can be obtained. Also, as will be shown below, there are special forests where the spirits live.

The river is also an important water source for the villagers, since that is where they bathe, wash clothes and obtain water for irrigation. In addition, as well as being important transportation networks, rivers are also crucial for the gathering of food such as fish and shellfish. Rice paddies are the place where rice, the staple food, is produced, but they are also where livestock are grazed in the dry season. Wetlands are also used as rice paddies, the plants that grow in and around wetlands being used for food and other purposes.

Subsistence rice farming is practiced in the village. Rice is produced in both swidden fields and wet rice paddies. Some villagers sell rice to households that have insufficient rice, but do not sell rice outside the village. Three main varieties are grown in swidden fields; Srov Kantrup, an

early-maturing variety (two-and-a-half months), Srov Kavet and Srov Kantrey, medium-maturing varieties (three months). Srov Kantrup has an especially good aroma, and Srov Kantrey is considered to have both a good flavor and good aroma. The farming tools include a long pointed wooden stick used to make holes for sowing rice seeds and bamboo containers for storing the rice seeds. For the first year in the cycle of a swidden rice field, small trees, shrubs and grass are slashed in February and burned in April. Weeding is done in May and rice is sown in June. Within the upland (swidden) rice field, farmers also grow pumpkins (Lapov in the Khmer language), bottle gourds (Khlauk), luffa gourds (Nornaung), lemon grass, Romdenh, chili, eggplants, long beans, and cucumbers in the burned areas or at the base of mounds. Swidden fields are not used to grow rice alone; they are also crucial as a place where subsistence vegetables are grown.

In the paddy fields, three early-maturing varieties, four medium-maturing varieties and one late-maturing variety are cultivated. One of the medium-maturing varieties, Srov Sken, has a hard grain and does not have a good flavor. However, the villagers grow it because it gives a good yield and can grow in a range of soil types. The timing of rice seedling transplantation is around July, sometime after the rainy season has started. The villagers produce cashew nuts and cassava for cash income. Villagers also keep a kitchen garden near their homes, where they grow herbs, leafy vegetables and other plants for everyday meals.

Apart from cultivating rice, the majority of farmers in Kbal Romeas Village also raise animals such as chickens, ducks, pigs and cattle for family consumption as well as for sale to generate additional cash income to support their livelihoods.

In the village, eight different kinds of fishing gear are used. Villagers who use fishhooks for fishing categorize them into seven different types. (See Appendix 3: Examples of Kbal Romeas Village Fishing Gear.)

Many Non-Timber Forest Products (NTFPs) are used in the village. The main items are edible tree fruit, edible mushrooms, items used for fuel, and items used as tools. (See Appendix 4: Examples of Kbal Romeas Village NTFPs.) Besides the forests, villagers also practice gathering in rivers, on river banks, as well as in and around paddy fields. Hunting is also carried out in the forests.

## Belief in spirits



In this village, there are many places concerning which the villagers hold beliefs in and they call those areas “Neakta”. “Neakta” is the “spirit of a place”.

In Kbal Romeas village, there are places known as Neakta Rompe Leu, Neakta Rompe

Kandal, Neakta Rompe Krom, Neakta Trapaing Thmar, Neakta Kbal Phum, Neakta Phnom Rerng, Neakta Sraeveng, Neakta Russey, Neakta Sraekranh, Neakta Sneng Krobey, Neakta Pha'em, Neakta Srae Keh Kom, Neakta Srae Pok, Neakta Kot Bou. The villagers believe that certain spirits live in these locations. In addition, places known as Tuol Yeay Keo and Rompe Kandal are grave forests. These beliefs are deeply embedded in the tradition of their ethnic group, and the people often go to pray and hold ceremonies in those places in order to live happy lives.

**Neakta Kbal Phum ---**Neakta Kbal Phum is located just outside the residential area of the village, and thus this spirit shrine is effectively at the entrance to the village. Villagers follow tradition scrupulously and worship this spirit according to the customs. They also organize spiritual ceremonies, especially when the cattle are lost, or people face problems such as illnesses. When they leave to go to their farmland, or when they return to the village, they always make an offering to this spirit.

Concerning this location, the villagers tell the following story.
"Once upon a time, a spirit (Neakta) "Neakta Vin" came to the villagers in a dream, saying that he wanted to live with the villagers and asking the villagers to construct a shrine for him. He said would take good care of the villagers and ensure their prosperity and happiness. They then prepared and constructed the shrine for him. Ever since then the villagers have lived happily, and have believed in and worshipped this spirit. Later, the villagers changed his name from "Neakta Vin" to "Neakta Kbal Phum"."

Kbal Romeas people believe that without Neakta Kbal Phum, their lives are not safe and they will become unhappy. Belief in Neakta Kbal Phum is important for villagers in expressing their identity as Bunong, an ethnic minority.



**The Grave Forest ---** When someone in the village passes away, the body is always buried in the grave forest, not cremated. Villagers do not know clearly how big the grave forest is, but it is quite large. At this grave hill, there are water jars, pots, plates, clothes, a crocodile-shaped flag, and other objects that are symbols of the graveyard. The grave forest is believed to be the place where the spirits of the deceased ancestors live. The villagers believe that it cannot be moved to a new location. In addition, if a person commits a wrongdoing such as taking water jars, pots, or plates away, or reconstructs the spirit house, he will have to atone for the wrongdoing by making an offering of pigs or buffaloes to pray to or apologize to the ancestors in order to prevent any suffering occurring to the villagers.

ឧបសម្ព័ន្ធ១៖

# ប្រតិទិនសកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃទៅតាមរដូវកាល

| សកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃ | ប្រភេទ/លម្អិត | កាលបរិច្ឆេទ | | | | | | | | | | | | ទីកន្លែង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| កសិកម្ម | | | | | | | | | | | | | | |
| ចម្ការស្រែដីខ្ពស់<br>ការដាំស្រូវចម្ការខុសគ្នាពីការធ្វើស្រែ ព្រោះយើងមិនចាំបាច់ភ្ជួររាស់ដី ឬសាបសំណាបទេ គឺគ្រាន់តែ ជំរះស្មៅឲ្យស្អាត ហើយចាប់ផ្ដើមដាំយកតែម្ដង | ការរៀបចំដីថ្មី<br>– កាប់រំលំដើមឈើធំៗ<br>– ដុតកម្ទេចចោល<br>– សំអាតស្មៅ | | x | x | x | x | | | | | | | | ភ្នំរីង ភ្នំគុយ |
| ជាធម្មតា ពួកយើងធ្វើចម្ការវិលជុំពី ២ ទៅ៣ឆ្នាំម្ដង។ | ការដាំ និងការប្រមូលផល<br>ក្រោយពីដាំរួចបានប្រហែល ១៥ ទៅ ២០ ថ្ងៃ ប្រជាជន ត្រូវសំអាតស្មៅបន្តបន្ទាប់ រហូតដល់ស្រូវដើម ឬមូលដើមទើបឈប់ធ្វើ | | | | | | x ការដាំ | | | | | | | |
| សំភារៈសម្រាប់ដាំមានឈើសំរួស ម្រាប់បុកដី និងបំពង់ ឬស្សីសម្រាប់ដាក់ពូជស្រូវ។ បើជាដីថ្មីចាប់ផ្ដើមកាប់ឈើធំៗនៅខែ២ | ស្រូវកន្ទ្រប់<br>ជាប្រភេទស្រូវស្រាលមានរយៈពេល២ ខែកន្លះ អង្ករទន់មានគ្រាប់ខ្លី ហើយបាយឆ្ងាញ់ ។ | | | | | | | | x ការប្រមូលផលផល | | | | | |
| រហូតដល់ខែ៤។<br>ការដុតរើចម្ការខែ៥ គឺចាប់ពីសំអាតស្មៅ ស្អាតរហូតដល់ខែ៦ទើបដាំស្រូវ។ | ស្រូវការ៉េត<br>ជាប្រភេទស្រូវកណ្ដាលមានរយៈពេល ៣ខែចាប់ផ្ដើមដាំពីខែ៦ហូតដល់ខែ៩ ទើបចាប់ផ្ដើមប្រមូលផល។ | | | | | | x ការដាំ | | | x ការប្រមូលផលផល | | | | |
| នៅក្នុងចម្ការដាំស្រូវនេះផងដែរ អ្នកភូមិយើងក៏ដាំ បន្លែដូចជា ល្ពៅ, ឃ្លោក, ននោង, ស្លឹកគ្រៃ, ម្ទេញ, ម្ទេស, ត្រប់, សណ្ដែកគួ, ត្រសក់, លាយឡំគ្នានៅក្នុងចម្ការនោះនៅតាមកន្លែងភ្លើងឆេះ ឬតាមជើងដីដំបូក។ | ស្រូវកន្ទ្រី<br>ជាប្រភេទស្រូវ កណ្ដាលមានរយៈពេល៣ខែដូចស្រូវការ៉េតដែរ។<br>អ្នកភូមិភាគច្រើនដាំស្រូវទាំងបីប្រភេទនេះព្រោះវាជាប្រភេទស្រូវដែលទន់ក្រអូបហើយបាយឆ្ងាញ់ទៀត។ | | | | | | x ការដាំ | | | x ការប្រមូលផលផល | | | | |

| សកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃ | ប្រភេទ/លម្អិត | កាលបរិច្ឆេទ | | | | | | | | | | | | ទីកន្លែង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| វាលស្រែដីទាប<br><br>នៅពេលដែលដីមិនបានប្រើប្រាស់សម្រាប់ធ្វើស្រែ<br>យើងបានប្រើវាសម្រាប់ជាកន្លែងព្រលែងសត្វ<br>ដូចជាសត្វគោក្របីជាដើម។ | ការរៀបចំដី<br>ច្រូតកញ្ចៀងស្រូវ ឬគល់ស្រូវ ហើយប្រមូលម្ដុំដើម្បីដុត។<br>ការភ្ជួរដី ហើយហាលដីក្រោមពន្លឺព្រះអាទិត្យដើម្បីសម្លាប់ស្មៅ និងរុក្ខជាតិតូចៗ។ | | | | | x | | | | | | | | ស្រែភូមិក្បាលរមាស<br>ស្រែរំពេរ<br>ស្រែព្រះផ្តេក |
| | ការភ្ជួររាស់<br>គេចាប់ផ្តើមភ្ជួរដាសដីចាប់ពីខែ៥ ដើម្បីហាលដី និងអោយស្មៅងាប់ ។ | | | | | x | | | | | | | | |
| | ធ្វើការជ្រើសរើសពូជ<br>ប្រហែលជា២សប្តាហ៍បន្ទាប់ពីការរៀបចំដីយើងចាប់ផ្តើមសាបពូជដែលជាម្ទតា នៅជាប់ជិតនឹងស្រែដែរ។ | | | | | | x | | | | | | | |
| | ការដាំពូជ និងការទទួលផល<br><br>ស្រូវនាងតី និងសែនពិ<br>ដោជាប្រភេទស្រូវស្រាលស្ទួងមានរយៈពេល២ខែកន្លះ។ | | | | | | | x ការដាំ | | x ការប្រមូលផលផល | | | | |
| | ស្រូវរំដួល+ផ្កាស្លា និងផ្កាម្លិះ<br>ជាប្រភេទស្រូវកណ្តាលហើយស្រូវទាំងបីប្រភេទនេះ ទន់ ក្រអូប ឆ្ងាញ់ និងលក់បានថ្លៃ។ | | | | | | | x ការដាំ | | | x ការប្រមូលផលផល | | | |
| | ស្រូវស្ពិន<br>ជាប្រភេទស្រូវកណ្តាលអង្កររាងរឹងមិនសូវឆ្ងាញ់តែគេនិយមដាក់ដោយសារផលច្រើន និងមិនរើសដី ។ | | | | | | | x ការដាំ | | | x ការប្រមូលផលផល | | | |

| សកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃ | ប្រភេទ/លម្អិត | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ទីកន្លែង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ស្រូវនាងណយ<br>ជាំប្រភេទស្រូវធ្ងន់មានរយះពេល៥ខែ អង្កររឹងឡើងឆ្នាំងមានដើមរឹងមាំ ហើយបានផលច្រើន។ | | | | | | | x ការដាំ | | | | x<br>ការប្រមូលផលផល | | |
| ចម្ការ | ស្វាយចន្ទី | | | | | | | | | | | | | |
| | – សម្អាតស្មៅ (វាអាស្រ័យលើចម្ការ ស្មៅច្រើនឬក៏តិច) | x | | | | | | | | | x | | | |
| | – ការរើសគ្រាប់ចាន្ទី។ | | x | x | x | | | | | | | | | |
| | ដំឡូងមី | | | | | | | | | | | | | |
| | – សម្រាប់ដីថ្មី, កាប់ព្រៃ និងដុត | | x | x | x | | | | | | | | | |
| | – ការដាំ | | | | x | x | | | | | | | | |
| | – ការសំអាតស្មៅត្រូវចាប់ផ្តើមបន្ទាប់ពីដំឡូងដុះឡើងផុតពីដី ដើម្បីកុំអោយស្មៅគ្របដណ្តប់។ | | | | | x | x | x | x | x | x | x | | |
| | – ការប្រមូលផលអាចចាប់ផ្តើមពីខែ១២ រហូតដល់ ខែ១។ | x | | | | | | | | | | | x | |
| សួនបន្លែនៅផ្ទះ | ស្ពៃ | x | x | x | | | | | | | | | | |
| | – ស្ពៃរៀបចំដីដូចត្រកួនដែរ ខុសត្រង់ស្ពៃយើងត្រូវសាបពូជលើករានផុតពីដីសាប<br>– ពូជបានពី១៥-២០ថ្ងៃទើបដកយកទៅដាំនៅលើរោងដែលបានរៀបចំរួច។<br>– ក្រោយពីដាំហើយត្រូវមើលថែដូចជាដាក់ជីកំប៉ុសស្រោចទឹកដកស្មៅជ្រោយដី។ | | | | | | | | | | | | | |

| សកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃ | ប្រភេទ/លម្អិត | កាលបរិច្ឆេទ | | | | | | | | | | | | ទីកន្លែង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| | ត្រកួន<br>ត្រកួនចាប់ផ្តើមរៀបចំដី<br>ដោយកាប់ឈើធ្វើរបង កាប់រោង<br>យកផេះមកលាយចូល<br>ដីដែលបានកាប់រួច។<br>២ថ្ងៃក្រោយបន្ទាប់ពីរៀបចំ<br>អាចធ្វើការដាំបាន។ មុនដាំយក<br>គ្រាប់ត្រកួតត្រាំជាមួយទឹកក្តៅអុនៗ<br>ប្រហែល ២ម៉ោងស្រង់ចេញ<br>ទុកអោយស្ងួតល្អ ទើប<br>យកទៅដាំលើរោងដែលបានកាប់រួច។<br>ស្រោចទឹកមុន<br>និងក្រោយពេលដាំ។បើយើងមើល<br>ថែបានល្អដូចជាស្រោចទឹកសំអាតស្មៅ<br>ជ្រោយដី ដាក់ដី<br>យើងអាចកាត់វាបានពី២ទៅ៣លើក។ | x | x | x | | x | x | x | | x | x | x | | |
| | ដំណាំដែលពេញនិយមផ្សេងទៀត<br>ត្រប់ | x | x | x | x | x | x | x | x | x | | | | |
| | ខ្ទឹម | x | x | x | | | | | | | | | | |
| | ម្ទេស | | | | | | | x | x | | | | | |
| | រំដេង | x | x | x | x | x | x | x | x | | | | | |
| | ល្ពៅ | | | | | x | x | x | | | | | | |
| | ត្រសក់ | x | x | x | x | | | | | | | | | |
| | សណ្តែកគួ | | | | | | | | | | | | x | |
| ការចិញ្ចឹមសត្វ<br>ក្រៅធ្វើស្រែចម្ការគ្រួសារភាគច្រើន | មាន់,ទា,ជ្រូក<br>មាន់ទាជ្រូកចិញ្ចឹមពេញមួយឆ្នាំ អ្នកខ្លះ<br>ចិញ្ចឹមក្នុងទ្រុង ខ្លះចង ខ្លះព្រលែង | x | x | x | x | x | x | x | x | x | x | x | x | វាលស្រែ និងក្នុងភូមិ |

| សកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃ | ប្រភេទ/លម្អិត | កាលបរិច្ឆេទ | | | | | | | | | | | | ទីកន្លែង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ធ្វើការចិញ្ចឹមសត្វ ដូចជា៖ មាន់ទា ជ្រូក គោ និងក្របី សម្រាប់ហូប និងលក់ គ្រាន់ជួយដោះស្រាយជីវភាពគ្រួសារ។ | ដោយក្នុង១ថ្ងៃ អោយចំនីមួយដង ទៅ២ដង ប្រភេទមាន់ស្រែទាកាប ជ្រូកកណ្តុរ ចិញ្ចឹមនៅស្រែ និងនៅក្នុងភូមិ។ | | | | | | | | | | | | | |
| | គោក្របី គោក្របីចិញ្ចឹមពេញមួយឆ្នាំ ដោយព្រលែងពេលព្រឹក ពេលល្ងាចទៅតាមរកមកវិញដោយ ដេញអោយចូលមកផ្ទះវិញ។ | x | x | x | x | x | x | x | x | x | x | x | x | ទួលពូលង និងស្រែវែងគោក្របីនៅត្រាំត្រពាំងក្រាញ់ ត្រពាំងកកោះ/ត្រពាំងត្បែង និងស្រែលាង។ |
| ក្រៅពីនេះសហគមន៍មួយចំនួនតូចក៏ប្រកបមុខរបរលក់ដូរបន្តិចបន្តួច ដូចជា អំបិល ប៊ីចេង នំ ទឹកក្រូច សាំង ម៉ាស៊ូត...។ | | | | | | | | | | | | | | |
| នេសាទ | | | | | | | | | | | | | | |
| សំណាញ់ | សំណាញ់ត្រីរៀល ភាគច្រើនអាចចាប់ត្រីមួយចំនួន ដូចជា ត្រីរៀល ត្រីស្លាត កូនត្រី អណ្តែង និងកូនត្រីឆ្លាំង។ | x | x | x | x | x | | | | | | | x | អូរព្រះផ្ដេក អូរកន្ត្រំ អូររំចេក ត្រពាំងក្រាញ់ និងកុតប៊ូ តាមដងទន្លេស្រែពក |
| | សំណាញ់ឡាក (ប្រភេសំណាញ់ក្រឡាធំ) ភាគច្រើនបង់នៅតាមអន្លង់កាំងជ័រ និងអាចចាប់ត្រីប៉ាវ៉ាមុខពីរ ត្រីគ្រសក់ ត្រីព្រួល ត្រីក្អែក ត្រីឆ្កិន ត្រីខ្លា ត្រីរមាសជាដើម។ | | x | x | x | x | | | | | | | | |
| | សំណាញ់ប្រយ៉ុង សំណាញ់ប្រភេទនេះ អាចចាប់បានត្រីផ្កាក្លូច ត្រីឆ្កិន ត្រីស្លាត ត្រីគ្រសេក ត្រីច្រកែង ត្រីការហែរ | | | x | x | | | | | | | | | តាមថ្ម គុម្ពអណ្តែង គុម្ពរ៉ៃ |
| មង | មងអាចចាប់បានត្រីក្អែក ត្រីប៉ាវ៉ា ត្រីឆ្កិន ត្រីប៉ាសាអ៊ី ត្រីគ្រសក់ ត្រីគុលរាំង ត្រីកេះ ....។ | | x | x | x | x | | | | | | | | ទន្លេស្រែពក |

| សកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃ | ប្រភេទ/លម្អិត | កាលបរិច្ឆេទ | | | | | | | | | | | | ទីកន្លែង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| សន្ទូច | សន្ទូចរនង<br>សម្រាប់ដាក់យកត្រីខ្យា, ត្រីឆ្លាំង, ត្រីក្លាំងហាយ, ត្រីឆ្តោរ។<br>នុយសម្រាប់សន្ទូចមានដូចជា ជន្លេន ផ្លែល្វា, ខ្យង ចង្រិត និងពេលខ្លះសាច់ត្រី។ | x | x | | | | | | | | | x | x | |
| | សន្ទូច បណ្តែត<br>ប្រើនុយដូចជា ផ្លែល្វា និងសាច់ត្រី)<br>ភាគច្រើនត្រីដែលជាប់សន្ទូចមាន ត្រីពោធិ៍ និងត្រីប្រា... | | | | | | | | x | x | x | | | |
| | សន្ទូចបោះ<br>ត្រីដែលជាប់សន្ទូចមាន ត្រីខ្យា ត្រីឆ្លាំង ត្រីកញ្ជ្រូកក្រហម ត្រីប្រា ត្រីកេះ ត្រីស្លាបមាន់ត្រីកញ្ចុះ ..។ | x | x | x | x | x | | | | | | | | ស្រះជ្រៅ |
| | សន្ទូចវាត់<br>ប្រភេទត្រី ដែលស៊ីសន្ទូចនេះ មានដូចជា ត្រីឆ្ពោ ត្រីឆ្លាំង ត្រីឆ្កិន ប្រភេទត្រីស្រកាតូច | | | | | | | x | x | x | x | | | |
| | សន្ទូចរៀម<br>ត្រីដែលស៊ីសន្ទូចប្រភេទនេះមានដូចជា ត្រីស្លាបមាន់ ត្រីកញ្ចុំជ័រ ត្រីចេកទុំ។ | | | | | | | x | x | x | x | | | |
| | សន្ទូចបង្កៃ (បង្កៃសន្ទូច)<br>ត្រីដែលស៊ីសន្ទូច ប្រភេទនេះ រួមមាន ត្រីអណ្តែង ត្រីរ៉ស,ត្រីឆ្លាំង, និងត្រីខ្ទឹង | x | x | x | x | x | x | x | x | x | x | x | x | អូរតូចៗ និង ត្រពាំង |
| | សន្ទូចបង្កៃ<br>ត្រីខ្យា, ត្រីប្រា, ត្រីពោ, ត្រីស្លាក់ធំៗ កូនត្រីអណ្តែង ត្រីក្រាញ់, (នុយ កង្កែប)។ | x | x | | | | | | | | | x | x | |
| តុម | ត្រីរៀល បង្កួយ ត្រីអាចម៍កុក | x | x | x | x | | | | | | | | | |
| ចាន់ | ចាប់បាន គន្ធាយ រំលេក អណ្តើកសង្កូល ត្រីខ្យា ត្រីស្លាក់ ត្រីត្រសក់ ត្រីឆ្តោរ ត្រីរមាស | x | | | | | x | x | x | x | x | x | x | ទន្លេ |

| សកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃ | ប្រភេទ/លម្អិត | កាលបរិច្ឆេទ | | | | | | | | | | | | ទីកន្លែង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ធ្នស់ | ត្រី ក្បាន ត្រីអណ្តែង ត្រីរ៉ស់...។ | | | | | | | | | | x | x | x | អូររំចេក អូក្រាញ |
| លាយ | ត្រី ក្បាន ត្រីអណ្តែង ត្រីរ៉ស់...។ | | | | | | | x | x | x | x | x | x | អូរ ស្រែវែង<br>អូក្បាលរមាស |
| ឈ្នាង | កម្ពឹស ក្តាម ខ្យង ត្រីច្រវ៉ា ត្រីក្រាញ់<br>ត្រីរ៉ស ត្រីអណ្តែង ត្រីឆ្លួញ | x | x | x | x | x | x | x | x | x | x | x | x | ត្រពាំងក្រាញ<br>និងត្រពាំងក្បាលរមាស |
| ប្រមូលផលអនុផលព្រៃឈើ | | | | | | | | | | | | | | |
| ព្រៃឈើ | ផ្លែឈើ | | | | | | | | | | | | | ភ្នំរឹង និងភ្នំបី |
| | – ផ្លែ ភៀវ | | | x | x | x | x | | | | | | | |
| | – ផ្លែគុយ | | | | | x | x | | | | | | | |
| | – ផ្លែពង្រ | | | x | x | | | | | | | | | |
| | – ផ្លែស្រម៉ | | | | | | | | | | x | x | x | |
| | – ផ្លែញ៉ | | | | | | | x | x | | | | | |
| | ជ័រស្ងួត | | | | | | | | | | | | | ស្រែធំ<br>ទួល,ត្រពាំងថ្ម,ភ្នំរឹង |
| | – ជ័រចុង | | | x | x | | | | | | | | | |
| | – ជ័រស្អុង | | | x | x | | | | | | | | | |
| | ជ័ររាវ<br>– ជ័រទឹក គេចោះធ្វើរនក្នុងដើមគ្រាច ឈើទាល រួចដុតប្រហែល៥នាទីទើបពន្លត់គេដង យកជ័រដែលចេញពីដើមឈើនោះ។ ប្រជាជនយកធ្វើចន្លុះដើម្បីលក់នៅទីផ្សា | x | x | x | | | | | | | x | x | x | កុតប៊ូ |
| | ផ្តៅ និងវល្លិ៍ដទៃទៀត<br>– ផ្តៅទឹក ផ្តៅភ្នំ ផ្តៅព្រៃ ហើយវល្លិ៍វាអាចយកមកទ្រុងមាន់ទារ | | | | | x | x | x | | | | x | x | ព្រៃក្រាញ និងព្រៃរឹង |
| | ផ្សិត<br>– រងា | | | | | | | | | | | x | x | ពាសពេញព្រៃ |
| | – ផ្សិតក្រោក | | | | | | x | x | | | | | | ទួលពូលូង |
| | – ផ្សិតប៉ក់<br>ផ្សិតប៉ក និងផ្សិតអំបោះ | | | | | x | x | | | | | | | ព្រៃក្រាញ និងព្រៃរឹង |

| សកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃ | ប្រភេទ/លម្អិត | កាលបរិច្ឆេទ | | | | | | | | | | | | ទីកន្លែង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ទន្លេ,ច្រាំងទន្លេ | ខ្ចៅ,គ្រុំ | | | x | x | | | | | | | | | ជួរក្រាញ់ ជួរប៉ោក |
| | បន្លែ<br>– ផ្កាអណ្ដែង | x | x | | | | | | | | x | x | x | កែងថ្ម |
| | ប្រភេទត្រពាំង<br>– ត្រពាំងស្រុក,ត្រពាំងឬស្សីព្រៃខ្ចី,ត្រពាំងឬស្សីព្រៃ,ត្រពាំងឬស្សីក្សីប និង ត្រពាំងឬស្សីព្រេច | | | | | x | x | x | x | x | | | | អូររំចេក អូរព្រះផ្ដែក និងតាមដងទន្លេស្រែពក |
| វាលស្រែ | ម្អម | | | | | x | x | x | x | x | x | x | x | |
| ប្រជាជនអាចធ្វើស្រែបានស្រូវហូបពេលមួយឆ្នាំ ក្រៅពីបានស្រូវ ហើយក៏ជាជំរកសំរាប់ ក្ដាម ខ្យង កង្កែប ហ៊ឹង និងត្រីផងដែរ | ក្ដាម ខ្យង | | | | | | x | x | | | | | | ស្រែជើងភូមិ ស្រែព្រះផ្ដែក និងស្រែរំពេ |
| | កង្កែប ហ៊ឹង | | | | | x | x | | | | | | | តាមស្រែ និង អូរ ល្វា |
| ការបរបាញ់សត្វ | | | | | | | | | | | | | | |
| | អណ្ដើក<br>- សង្កូល ព្រិច ...ធ្វើម្ហូប សេក កគូរ ដុះ | | | | | | | | | | | x | x | ទូល ពូលូង ភ្នំរឹង និងព្រៃអូរផ្ដៅ |
| | ត្រកួត | | | | | x | x | | | | | | | ព្រៃអូរផ្ដៅ ព្រៃរោងយួន |
| | ឈ្លូស | x | x | x | x | x | x | x | x | x | x | x | x | ទូលស្រែវែង ទួលពូលូង និងភ្នំបី |
| | ជ្រូកព្រៃ | x | x | x | x | x | x | x | x | x | | | | អូររោងយួន ស្រែធំ |
| | សារិកាកែវ | | | x | x | x | x | | | | | | | ជុំវិញភូមិ |
| | ឃ្មុំ<br>- ឃ្មុំខែចេត្រ<br>- ឃ្មុំរងារ | | | x | x<br>x | | | | | | | | x | អូរផ្ដៅ |

ក្រៅពីការងារទាំងនេះ យើងក៏បានចូលរួមសកម្មភាពសង្គមដូចជាពិធីបុណ្យទានផ្សេងៗ និងចូលរួមប្រជុំផ្សេងៗជាមួយ អាជ្ញាធរភូមិ និងអង្គការសង្គមស៊ីវិល។

**Appendix 1**

# Kbal Romeas Village SEASONAL LIVELIHOOD CALENDAR

| Livelihood activities | Type/details | Months | | | | | | | | | | | | Locations* |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | |
| Agriculture | | | | | | | | | | | | | | |
| Upland rice farming<br>There is no need to do land preparation (ploughing and harrowing) or raise seedlings. Farmers simply need to do weeding. After weeding, rice seed can be directly planted.<br><br>Normally, farmers rotate rice farming land every 2-3 years.<br><br>Within the upland rice field, farmers also grow pumpkins, bottle gourds, luffa gourds, lemon grass, Romdenh (*Probably Planchonella obovate*), chili, eggplants, long beans, and cucumbers in the burned areas or at the base of mounds | New land preparation<br>– Slashing wood shrubs<br>– Burning<br>– Weeding | | x | x | x | x | | | | | | | | Roeng and Kuy Mountain |
| | Planting and Harvesting<br>(*weeding before and 15–20 days after planting until the booting stage)<br>Srov Kantrup<br>An early-maturing variety (two and-a-half months). Grain is short, soft and has a good flavor. | | | | | | x Planting | | x Harvesting | | | | | |
| | Srov Kavet<br>A medium-maturing variety (three months). Planted in June and harvested in September. | | | | | | x Planting | | | x Harvesting | | | | |
| | Srov Kantrey<br>A medium-maturing variety, as with Srov Kavet (three months). Farmers generally grow these three varieties because the grains are soft, fragrant and delicious. | | | | | | x Planting | | | x Harvesting | | | | |
| Lowland rice<br><br>When land is not being used, it is used for grazing livestock such as cows. | Land Preparation<br><br>Cutting and burning stubble<br>(If left long) cut stubble and gather it at the center of rice field for burning<br>Ploughing<br>To expose soil to the sun and to kill weeds | | | | | x<br>x | | | | | | | | Srae Phum Kbal Romeas, Srae Rum Pe, Srae Preah Pha Ek |
| | Raising seedlings<br>About 2 weeks after land preparation, we start raising seedlings, normally next to the rice field. | | | | | | x | | | | | | | |
| | Planting seedlings and harvesting<br><br>Srov Neang Tey and Sen Pidor<br>Early-maturing varieties (two-and-a-half months) | | | | | | | x Planting | | x Harvesting | | | | |

| Livelihood activities | Type/details | Months 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | Locations* |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | Rumduol, Phka Sla, Phka Malis<br>Medium-maturing varieties. The grains are soft, fragrant, and have a good flavor when cooked. | | | | | | | x Planting | | | x Harvesting | | | |
| | Srov Sken<br>Medium-maturing variety. The grains are hard when cooked and not delicious. Farmers grow it because it gives a good yield and can grow in a range of soil types. | | | | | | | x Planting | | | x Harvesting | | | |
| | Srov Neang Noy<br>A late-maturing variety (five months). Grains are not soft, and expand when cooked. The tillers are rigourous and it gives a good yield. | | | | | | | x Planting | | | | x<br>Harvesting | | |
| Farming | Cashew (a cash crop)<br>Weeding (depends on weed density)<br>Collecting cashew fruits | x | x | x | x | | | | | | x | | | |
| | Cassava (a cash crop)<br>– For new land, clear and burn land<br>– Planting<br>– Weeding<br>– Harvest | x | x<br>x | x | x | x | x | x | x | x | x | x | x | |
| Kitchen gardens | Pak choi (ver.)<br>– Farmers need to raise a soil bed, and apply ash to the prepared soil, establishing a nursery above the ground for raising seedlings.<br>– 15–20 days after seeding, farmers uproot seedlings and transplant them into the soil bed.<br>– After transplanting, farmers need to take care of the crop including application of compost, watering, weeding and cultivating the soil . | x | x | x | | | | | | | | | | |
| | Morning glory<br>– Farmers need to raise a soil bed, and apply ash to the prepared soil, and two days later, the seed can be planted. Before planting, seed needs to be soaked in warm water for two hours, and then taken away to be properly dried. The garden is watered before and after planting. With proper care | x | x | x | | x | x | x | | x | x | x | | |

| Livelihood activities | Type/details | Months 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | Locations* |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | (watering, weeding, stirring up the soil, fertilization), farmers can harvest two to three times a year. | | | | | | | | | | | | | |
| | Other popular vegetables to plant | | | | | | | | | | | | | |
| | eggplants | x | x | x | x | x | x | x | x | x | | | | |
| | garlic | x | x | x | | | | | | | | | | |
| | chili | | | | | | | x | x | | | | | |
| | ginger | x | x | x | x | x | x | x | x | | | | | |
| | turmeric | | | | | x | x | x | | | | | | |
| | cucumbers | x | x | x | x | | | | | | | | | |
| | long beans | | | | | | | | | | | | x | |
| Animal raising<br><br>For family consumption as well as for sale to generate additional income to support livelihoods. | Chickens, ducks and pigs<br>– Raised in a pen or are free-range. For pigs, sometimes they are tied with wire. They are fed once or twice a day.<br>– Local chicken breeds, broiler ducks, and locally bred pigs | x | x | x | x | x | x | x | x | x | x | x | x | In rice fields and in the village. |
